ទំនុកដំកើង១២៤-១៣១

# ជំពូក ១២៤

*ឆាកចង់ ក្រោកឡូងទៅ*

ជំពូក១២៤ ជាឯកសារប្រវត្តិសាស្ត្រ។ ជំពូកនេះ រំឮកពីហេតុការណ៍ព្រះជាម្ចាស់ផ្តល់សេចក្តីមេត្តាករុណាក្នុងគ្រាកន្លងផុតទៅ។

**[1]បើមិនមែនជាព្រះយេហូវ៉ាដែលកាន់ខាងពួកយើង នោះគួរឱ្យ
អ៊ីស្រាអែលនិយាយឥឡូវថា [2]បើមិនមែនជាព្រះយេហូវ៉ាដែល
កាន់ខាងពួកយើងទេ ក្នុងកាលដែលមនុស្សបានលើកគ្នាទាស់នឹង
យើង [3]នោះប្រាកដជាគេបានលេបយើងទាំងរស់ហើយ គឺក្នុង
កាលដែលសេចក្តីក្រោធរបស់គេ បានក្តៅឡើងទាស់នឹងពួកយើង
(ទំនុកដំកើង១២៤:១-៣)។**

ពេលសាសន៍អ៊ីស្រាអែលនាំគ្នាចូលមកថ្វាយបង្គំព្រះអង្គ គេពិចារណាមើលកាលគ្រាកន្លងទៅ។ ព្រះជាម្ចាស់បានផ្តល់ព្រះគុណដល់គេ ទើបគេមានឯកសិទ្ធិចូល

មកថ្វាយបង្គំព្រះអង្គនៅទីក្រុងយេរូសាឡិមក្នុងពេលនេះ។ ដោយសារមូលហេតុនោះ សាសន៍អ៊ីស្រាអែលនាំគ្នាថ្វាយពាក្យអរព្រះគុណដល់ព្រះជាម្ចាស់។

**យ៉ាងនោះ ប្រាកដជាទឹកជំនន់បានលិចយើង គឺទឹកជ្រោះបានហូរមកគ្របលើព្រលឹងយើងហើយ (ទំនុកដំកើង១២៤:៤)។**

"ទឹក" ដែលសម្ដែងនៅក្នុងខខាងលើ គឺជាទឹកសមុទ្រក្រហម ទឹកទន្លេយ័រដាន់ និងស្ថានការណ៍ផ្សេងៗទៀត ដែលសាសន៍អ៊ីស្រាអែលបានឆ្លងកាត់កន្លងមក។

**សូមឲ្យព្រះយេហូវ៉ាបានប្រកបដោយព្រះពរ ដែលទ្រង់មិនបានប្រគល់ពួកយើង ឲ្យជារំពាដល់ធ្មេញគេ (ទំនុកដំកើង១២៤:៦)។**

សាសន៍អ៊ីស្រាអែលទទួលស្គាល់ថា ព្រះជាម្ចាស់បានជួយដល់សាសន៍នេះ ទើបគេអាចរស់រានមានជីវិតមកទល់ពេលបច្ចុប្បន្ន។

**ឯសេចក្ដីជំនួយរបស់យើង គឺដោយពឹងដល់ព្រះនាមព្រះយេហូវ៉ា ដែលទ្រង់បានបង្កើតផ្ទៃមេឃ នឹងផែនដី (ទំនុកដំកើង១២៤:៨)។**

សាសន៍អ៊ីស្រាអែលថ្វាយបង្គំដល់ព្រះអង្គនិម្មាបនិក គឺជាអង្គដែលទ្រង់បង្កើតផ្ទៃមេឃនិងផែនដី។

# ជំពូក ១២៥

*ណាទចនា បទចម្រៀងសុវត្ថិភាព*

ជំពូក១២៥ បរិយាយពីក្បួនព្យុហយាត្រាពេលបានធ្វើដំណើរមកដល់ទីមួយដែលគេអាចមើលឃើញភ្នំស៊ីយ៉ូន។ កំពុងតែភ្នែកគេសម្លឹងឃើញភ្នំស៊ីយ៉ូន ចិត្តរបស់គេមានសេចក្តីសង្ឃឹមយ៉ាងខ្លាំងទៅគ្រាអនាគត។ ចិត្តយើងគ្រប់គ្នាក៏យ៉ាងដូច្នោះដែរ កាលណាយើងមានទីសង្ឃឹមនៅក្នុងព្រះអម្ចាស់យេស៊ូវ ចិត្តរបស់យើងមានសុទិដ្ឋិនិយមយ៉ាងខ្លាំង ពីហេតុការណ៍ដែលកើតឡើងនៅគ្រាអនាគត។ ព្រះជាម្ចាស់ដែលទ្រង់បានជួយយើងកាលពីគ្រាអតីតកាល ព្រះអង្គនៅតែបន្តជួយយើងរហូតដល់គ្រាអវសាន្តនៅពេលអនាគត។ គម្ពីរភីលីព១:៦សម្តែងថា "ខ្ញុំជឿសេចក្តីនេះជាយ៉ាងជាក់ថា ព្រះអង្គដែលទ្រង់បានចាប់តាំងធ្វើការល្អក្នុងអ្នករាល់គ្នា ទ្រង់នឹងធ្វើឱ្យកាន់តែពេញខ្នាតឡើង ទាល់តែដល់ថ្ងៃនៃព្រះយេស៊ូវគ្រីស្ទ"។ យើងអាចអោយចំណងជើងជំពូក១២៥ថា ជាបទចម្រៀងសុវត្ថិភាព។ មិនតែប៉ុណ្ណោះ ជំពូក១២៥ ជាបទទំនាយស្តីពីការស្តារឡើងវិញនូវស្ថានភាពរបស់នគរអ៊ីស្រាអែល។

**ពួកអ្នកដែលទុកចិត្តនឹងព្រះយេហូវ៉ា គេដូចជាភ្នំស៊ីយ៉ូន ដែលនឹង**

**រង្គើមិនបាន គឺបានជាប់នៅជាដរាប (ទំនុកដំកើង១២៥:១)។**

សាសន៍អ៊ីស្រាអែលមូលគ្នាមកពីគ្រប់ខេត្ត គ្រប់ស្រុក ដើម្បីចូលមកថ្វាយបង្គំព្រះអង្គនៅទីក្រុងយេរូសាឡិម។ នៅពេលគេធ្វើដំណើរមកឃើញខ្នងភ្នំជុំវិញទីក្រុងយេរូសាឡិម ចិត្តគេមានសេចក្តីរីករាយយ៉ាងខ្លាំង។ ពេលនេះ គេបានចូលមកកាន់តែជិតទីក្រុងយេរូសាឡិម ឯភ្នែកគេក៏បានឃើញទីក្រុងនោះយ៉ាងជាក់ច្បាស់ផងដែរ។

**មានភ្នំនៅព័ទ្ធជុំវិញក្រុងយេរូសាឡិមយ៉ាងណា នោះព្រះយេហូវ៉ាក៏គង់នៅជុំវិញរាស្ត្រទ្រង់យ៉ាងនោះដែរ ចាប់តាំងពីឥឡូវនេះ ដរាបដល់អស់កល្បជានិច្ច (ទំនុកដំកើង១២៥:២)។**

ខខាងលើ ជាយុថ្កាដ៏រឹងមាំសម្រាប់ជំនឿរបស់យើងលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ អស់អ្នកណាដែលទុកចិត្តលើព្រះយេហូវ៉ា អ្នកនោះមិនត្រូវរង្គើឡើយ ទោះបីភ្នំរង្គើក៏ដោយ សេចក្តីសង្ឃឹមរបស់គេនៅនឹងថ្កល់ ធ្ងន់ជាងភ្នំទៅទៀត។ ជំនឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ នាំមកនូវសេចក្តីសង្ឃឹមដ៏រឹងមាំជាងបូសថ្មដា។

# ជំពូក ១២៦

*ឆាចឆនា សេចក្តីរីករាយចិត្ត ក្រោយត្រឡប់ពីប្រទេសបាប៊ីឡូន*

**កាលព្រះយេហូវ៉ា ទ្រង់បាននាំពួកឈ្លើយមកឯក្រុងស៊ីយ៉ូនវិញ នោះយើងរាល់គ្នាបានដូចជាមនុស្សដែលយល់សប្តិទេ (ទំនុកដំកើង១២៦:១)។**

បទពិសោធន៍ដែលសាសន៍អ៊ីស្រាអែលកំពុងតែជួបប្រទះក្នុងគ្រានេះ ធ្វើអោយគេមិនជឿភ្នែកគេថាបានឃើញហេតុការណ៍ដែលកំពុងតែកើតឡើងនេះទេ។ គេនាំគ្នាធ្វើដំណើរត្រឡប់មកពីប្រទេសបាប៊ីឡូនវិញ ឆ្ពោះទៅកាន់ទីក្រុងយេរូសាឡិម។ រឿងដែលកំពុងកើតឡើងនេះ ប្រៀបឧបមាដូចជាយល់សប្តិ។

**គ្រានោះ មាត់យើងបានពេញដោយការសើចសប្បាយ ហើយអណ្តាតក៏ពេញដោយបទចំរៀង នោះនៅគ្រប់ទាំងសាសន៍មានគេថា ព្រះយេហូវ៉ាទ្រង់បានធ្វើការយ៉ាងធំសំរាប់ពួកនោះពិត (ទំនុកដំកើង១២៦:២)។**

ដោយសារមូលហេតុខាងលើ សាសន៍អ៊ីស្រាអែលចង់ធ្វើទីបន្ទាល់ប្រាប់ដល់មនុស្សក្នុងលោកថា ព្រះយេហូវ៉ាទ្រង់ល្អចំពោះរាស្ត្ររបស់ព្រះអង្គ។

**ព្រះយេហូវ៉ាបានធ្វើការយ៉ាងធំសំរាប់យើងមែន យើងក៏អរណាស់ដែរ (ទំនុកដំកើង១២៦:៣)។**

ជំពូក១២៦ មិនមែនគ្រាន់តែបរិយាយពីដំណើរដែលសាសន៍អ៊ីស្រាអែលមានឯកសិទ្ធិត្រឡប់មកនៅប្រទេសរបស់ខ្លួនវិញទេ។ សាសន៍អ៊ីស្រាអែលត្រូវសាសន៍បាប៊ីឡូនដឹកយកទៅធ្វើជាឈ្លើយសឹក នៅក្នុងប្រទេសនោះអស់រយៈពេលជាច្រើនឆ្នាំ។ លុះគម្រប់ពេលវេលាដែលព្រះជាម្ចាស់កំណត់ ព្រះអង្គបានបើកអោយគេត្រឡប់មកស្រុករបស់គេវិញ។ មែនហើយជំពូក១២៦ ជាទំនុកច្រៀងតាមថ្នាក់ ស្តីពីការធ្វើដំណើរត្រឡប់មកពីប្រទេស ដែលសាសន៍អ៊ីស្រាអែលធ្វើជាខ្ញុំគេ មកឯប្រទេសដែលមានសេរីភាពវិញ។ ប៉ុន្តែ បទគម្ពីរនេះមិនមែនមានន័យត្រឹមតែប៉ុណ្ណោះឡើយ។ ជំពូក១២៦ ជាបទទំនាយស្តីពីការស្តារសាសន៍អ៊ីស្រាអែលអោយមានភាពរុងរឿងឡើងវិញ នៅពេលព្រះអម្ចាស់យេស៊ូវយាងមកគ្រងរាជ្យនៅលើផែនដីនេះ។

**"ឱព្រះយេហូវ៉ាអើយ សូមនាំពួកយើងខ្ញុំដែលជាឈ្លើយឱ្យត្រឡប់មកវិញ ដូចជាទឹកជ្រោះនៅស្រុកខាងត្បូង "អស់អ្នកដែលសាប**

**ព្រោះ ដោយស្រក់ទឹកភ្នែក នោះនឹងបានច្រូតវិញ ដោយច្រៀងអរសប្បាយ ៦ឯអ្នកដែលកណ្តៀតពូជ សំរាប់សាបព្រោះចេញទៅទាំងយំ នោះប្រាកដជានឹងចូលមកវិញដោយអំណរ ព្រមទាំងយកកណ្តាប់មកផង (ទំនុកដំកើង១២៦:៤-៦)។**

អ្នកប្រាជ្ញគម្ពីរមួយរូបនាមបណ្ឌិតហ្គែបឺរឡេន បានបកស្រាយខខាងលើដូចខាងក្រោមនេះ "ទំនុកដំកើងជំពូក១២៦ ជាបទទំនាយសម្រាប់សាសន៍អ៊ីស្រាអែលក្នុងគ្រាអនាគត។ ប៉ុន្តែ ជំពូកនេះមានខ្លឹមសារយ៉ាងជ្រាលជ្រៅសម្រាប់រាស្ត្ររបស់ព្រះអង្គគ្រប់ជាតិ គ្រប់សាសន៍ គ្រប់កាលសម័យ។ ដើម្បីអោយរាស្ត្ររបស់ព្រះជាម្ចាស់គ្រប់ជាតិសាសន៍ មានឯកសិទ្ធិចូលទៅទទួលសេចក្តីរីករាយអរសប្បាយនៅក្នុងរាជ្យទ្រង់ ព្រះអម្ចាស់យេស៊ូវគ្រីស្ទត្រូវយាងមកដើម្បីទទួលភាពទន់ទាបទាំងអម្បាលមាណ ដែលមនុស្សលោកបានធ្វើដល់ទ្រង់។ ព្រះអង្គបានយករូបអង្គទ្រង់ធ្វើជាពូជព្រោះចូលទៅក្នុងចិត្តមនុស្ស ដើម្បីអោយគេទទួលព្រះអង្គធ្វើជាអង្គសង្គ្រោះ។ ពេលព្រះអង្គយាងមកយកនិស្ស័យជាមនុស្សជាតិនៅលើលោកនេះ ព្រះអង្គទ្រង់ព្រះកន្សែងសោកជាច្រើនលើកច្រើនសារ។ ព្រះអង្គព្រះកន្សែងសោកសម្រាប់ពួកទីក្រុងយេរូសាឡិម សម្រាប់មនុស្សក្នុងលោក ក្នុងសេចក្តីអធិស្ឋានដែលទ្រង់បានព្រះកន្សែងសោកយ៉ាងខ្លាំង។ បើព្រះជាម្ចាស់នៃយើងទ្រង់ព្រះកន្សែងសោកយ៉ាងខ្លាំង ដើម្បីព្រោះពូជដំណឹងល្អដល់មនុស្សលោកយើងជាកូនរបស់ព្រះអង្គ ត្រូវធ្វើតាមលំអានដែលព្រះអង្គបានធ្វើដែរ។ សូមយើង

ព្រោះពូជទាំងឃំ ដ្បិតដល់កាលកំណត់ពូជដែលយើងព្រោះ នឹងបង្កើតជាផលផ្លែជាមិនខាន។ គម្ពីរកាឡាទី៦:៩បានសម្តែងថា “កុំឱ្យយើងណាយចិត្តនឹងធ្វើការល្អឡើយ ដ្បិតបើមិនរសាយចិត្តទេ នោះដល់កំណត់យើងនឹងច្រូតបានហើយ”។

# ជំពូក ១២៧

***ឆាចចនា*** *គ្មានព្រះ អ្វីៗទាំងអស់ត្រូវសាបសូន្យ*

ជំពូក១២៧ ជាទំនុកច្រៀងតាមថ្នាក់នៅក្នុងចង្កោមជំពូកទាំងដប់ប្រាំ។ ក្រុមព្យុហយាត្រាបានធ្វើដំណើរមកដល់បេះដូងនៃទីក្រុងយេរូសាឡិម ពោលគឺវិហារសាឡូម៉ូន។ នៅពេលនោះចិត្តរបស់បណ្ដាជនដែលដើរក្នុងព្យុះហយាត្រា មានអារម្មណ៍ហាក់ដូចជាគេបានឡើងទៅដល់ស្ថានសួគ៌។ ជំពូក១១៧ មានអត្ថប្រយោជន៍ក្នុងជីវិតយើងសព្វថ្ងៃដែរ។ ការពឹងពាក់លើព្រះជាម្ចាស់ទាំងស្រុង ក្នុងការធ្វើដំណើរមួយជីវិតនេះ យើងត្រូវសម្លឹងភ្នែកទៅឯព្រះជាម្ចាស់ដែលគង់នៅស្ថានសួគ៌។ ចំណងជើងនៃជំពូក១២៧ យើងឃើញថា ទំនុកច្រៀងតាមថ្នាក់ជាបទរបស់ស្ដេចសាឡូម៉ូន។ បើតាមចំណងជើងនេះ យើងមើលទៅហាក់ដូចជាបទទំនុកដំកើងរបស់ស្ដេចសាឡូម៉ូន។ តាមពិតបុត្ររបស់ព្រះបាទដាវីឌដែលរៀបរាប់នៅក្នុងខនេះ និយាយសំដៅទៅអង្គព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់ប្រសូតមកតាមជំនួរវង្សរបស់ស្ដេចដាវីឌ។

**១ បើងគ្មានព្រះយេហូវ៉ាសង់ផ្ទះឡើង នោះពួកជាងដែលសង់ គេ**
**ធ្វើការជាឥតប្រយោជន៍ទេ បើគ្មានព្រះយេហូវ៉ាថែរក្សាទីក្រុង**

**នោះពួកយាមល្បាតគេចាំយាមជាឥតប្រយោជន៍ដែរ ២ការដែលឯងក្រោកឡើងមុនកំណត់ ហើយក្រចូលដេកពេលយប់ ព្រមទាំងបរិភោគដោយធ្វើការនឿយហត់ផង នោះជាការឥតប្រយោជន៍ទៀត ដ្បិតទ្រង់ប្រោសប្រទានឱ្យពួកស្ងួនភ្ងារបស់ទ្រង់ បានដេកលក់សប្បាយ (ទំនុកដំកើង១២៧:១-២)។**

ពាក្យថា "ឥតប្រយោជន៍"មានប្រើចំនួនបីដងនៅក្នុងជំពូកទាំងមូល។ សេចក្តីនេះចង់បញ្ជាក់ថា ក្នុងគ្រប់អ្វីៗទាំងអស់ដែលយើងឃើញមាននៅលើលោកយើងនេះ បើគ្មានព្រះជាម្ចាស់គង់ជាមួយរបស់នោះ កិច្ចការនោះ ជននោះសុទ្ធតែកំពុងស្ថិតនៅក្នុងភាពឥតប្រយោជន៍។ អ្វីៗទាំងអស់ដែលជាផ្នែកនៃជីវិតរបស់មនុស្សលោក ស្ថិតនៅលើព្រះពរដែលមកពីស្ថានលើតែម្យ៉ាងប៉ុណ្ណោះ។ សុភាសិតសាសន៍អាល្លឺម៉ង់ ពោលថា "ការកើតមកស្រេចលើជំហរ ការលូតលាស់ល្អស្រេចពរនៃព្រះ"។ យើងត្រូវសង្ឃឹមលើព្រះពររបស់ព្រះជាម្ចាស់ទើបដៃរបស់យើងធ្វើសម្រេចបានការល្អជាច្រើន។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទមានបន្ទូលថា "ដូច្នេះ កុំឱ្យខ្វល់ខ្វាយថា តើត្រូវបរិភោគអ្វី ឬស្លៀកពាក់អ្វីនោះឡើយ ដ្បិតគឺជាសាសន៍ដទៃទេតើ ដែលខំស្វែងរករបស់ទាំងនោះវិញ ឯព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌ ទ្រង់ជ្រាបហើយ ថាអ្នករាល់គ្នាត្រូវការនឹងរបស់ទាំងនោះដែរ ចូរស្វែងរកនគរ នឹងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង ដូច្នេះ កុំឱ្យខ្វល់ខ្វាយ

នឹងថ្ងៃស្អែកឡើយ ពីព្រោះថ្ងៃស្អែកនឹងខ្វល់ខ្វាយ ចំពោះការរបស់ថ្ងៃនោះឯង សេចក្តីលំបាកនៅថ្ងៃណា នោះគឺល្មមត្រឹមថ្ងៃនោះហើយ” (ម៉ាថាយ៦:៣១-៣៤)។

ម្យ៉ាងវិញទៀត ជំពូក១២៧បរិយាយពីកូននៅក្នុងគ្រួសារនីមួយៗ។ នៅពេលសាសន៍អ៊ីស្រាអែលនាំគ្នាឡើងទៅថ្វាយបង្គំព្រះជាម្ចាស់នៅទីក្រុងយេរូសាឡិម គេនាំប្រពន្ធ នាំកូនជាគ្រួសាររបស់គេទៅជាមួយដែរ។

> **មើល កូនចៅជាមរដកមកពីព្រះយេហូវ៉ា ហើយផលកើតពីផ្ទៃ ក៏ជារង្វាន់ដែលទ្រង់ប្រទានដែរ (ទំនុកដំកើង១២៧:៣)។**

ខខាងលើសម្តែងថា បុរសៗដែលធ្វើដំណើរទៅទីក្រុងយេរូសាឡិមនាំយកភរិយា នាំយកកូនចៅរបស់ខ្លួនដើម្បីថ្វាយបង្គំ និងថ្វាយពាក្យអរព្រះគុណដល់ព្រះជាម្ចាស់។

> **៤កូនដែលឯងបង្កើតពីកាលនៅក្មេង នោះធៀបដូចជាព្រួញនៅដៃនៃមនុស្សខ្លាំងពូកែ ៥សប្បាយហើយ អ្នកណាដែលមានបំពង់ព្រួញពេញ ដោយព្រួញយ៉ាងនោះ កាលណាត្រូវការនិយាយនឹងខ្មាំងសត្រូវនៅមាត់ទ្វារក្រុង នោះឯងមិនត្រូវខ្មាសឡើយ (ទំនុកដំកើង១២៧:៤-៥)។**

គ្រួសារណាដែលមានកូនប្រកបដោយព្រះគុណរបស់ព្រះជាម្ចាស់ តែងការពារគ្រួសាររបស់ខ្លួន។ បើមានកូនខំបម្រើព្រះអង្គ នោះជាកិត្តិយសការពារដល់គ្រួសារយើងរៀងៗខ្លួន។ កូនដែលធំដឹងក្ដីឡើងប្រកបដោយព្រះគុណរបស់ព្រះជាម្ចាស់រាប់ថាជាមរតកយ៉ាងមានតម្លៃជាទីបំផុតសម្រាប់គ្រួសារនីមួយៗ។

# ជំពូក ១២៨

***ឆាទចនា*** *គេហដ្ឋានផ្អែមល្ហែម*

បណ្ឌិតម៉ាទីន-លូធ័រ បានអោយចំណងជើងគម្ពីរទំនុកដំកើងជំពូក១២៨ថា "ចម្រៀងសម្រាប់គ្រួសារ"។ ជំពូកនេះបរិយាយពីគ្រួសារមួយដែលមានសុភមង្គល។ ឯសុភមង្គលនោះទៀតសោត គឺទទួលបានមកពីព្រះពររបស់ព្រះជាម្ចាស់។ សុភមង្គលនៃគ្រួសារស្ថិតនៅលើព្រះពររបស់ព្រះជាម្ចាស់ ដែលបានផ្តល់មកដល់គ្រួសារមួយនោះ។ សូមយើងពិចារណាអោយបានល្អិតល្អន់ពីគ្រឹះ ដែលញុំាងអោយគ្រួសារនីមួយៗមានសុភមង្គល។ តើគ្រឹះនៃគ្រួសារគឺអ្វី បានជាគេអាចទទួលសុភមង្គលនៅក្នុងគ្រួសាររបស់គេ?

**មានពរហើយអស់អ្នកដែលកោតខ្លាចដល់ព្រះយេហូវ៉ា ជាពួកអ្នកដែលដើរតាមផ្លូវរបស់ទ្រង់ (ទំនុកដំកើង១២៨:១)។**

តើធ្វើដូចម្តេចដើម្បីអោយគ្រួសារមួយមានសុភមង្គល? គ្រួសារដែលមានសុភមង្គលអាស្រ័យទៅលើគ្រឹះ ដែលគេយកគ្រួសារនោះសង់ពីលើ។ សុភមង្គលនៃ

មូលដ្ឋានគ្រឹះនៃសុភមង្គលរបស់គ្រួសារ ស្ថិតនៅលើសេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា។ កាលណាគ្រួសារទាំងមូល ដែលមានសមាជិកក្នុងគ្រួសារនីមួយៗ គឺប្ដី ប្រពន្ធ កូន ជាអ្នកកោតខ្លាចដល់ព្រះយេហូវ៉ា គ្រួសារនោះរស់នៅដោយសុខដុមរមនា និងមានសុភមង្គលយ៉ាងត្រជាក់ត្រជុំជាទីបំផុត។ នៅពេលរៀបអាពាហ៍ពិពាហ៍ដល់កូនប្រុស កូនស្រី គេច្រើនយកផ្លែដូង ផ្លែចេកមកបាញ់ថ្នាំទឹកមាស ទឹកប្រាក់ដោយជឿថា គ្រួសារមានសុភមង្គលដោយសារដុំមាស ដុំប្រាក់។ ទ្រព្យសម្បត្តិតែមួយមុខគត់ មិនអាចផ្ដល់សុភមង្គលដល់គ្រួសារបានទេ។ សេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា នាំមកនូវសុភមង្គលដល់គ្រួសារនីមួយៗ ទោះគ្រួសារនោះមានឬក្រក៏ដោយ។ គ្រួសារដែលមានសុភមង្គល គឺជាគ្រួសារដែលមានសេចក្ដីកោតខ្លាចដល់ព្រះយេហូវ៉ា។

**ដ្បិតឯងនឹងបានបរិភោគផលនៃកំឡាំងដៃឯង ឯងនឹងបានសប្បាយ ហើយនឹងមានសេចក្ដីសុខផង (ទំនុកដំកើង១២៨:២)។**

ម្យ៉ាងវិញទៀត សុភមង្គលរបស់គ្រួសារកើតឡើងដោយសារសមាជិកគ្រួសារនីមួយៗស្គាល់តួនាទីរបស់ខ្លួន។ ខខាងលើសម្ដែងពីតួនាទីរបស់ប្ដី។ ប្ដីចាំបាច់ត្រូវធ្វើការរកស៊ីដើម្បីផ្គត់ផ្គង់ដល់គ្រួសាររបស់ខ្លួន។

**ប្រពន្ធឯងនឹងបានដូចជាដើមទំពាំងបាយជូរមានផ្លែ ដែលដាំនៅ**

**ក្នុងទីធ្លានៃផ្ទះឯង កូនឯងទាំងប៉ុន្មាន នឹងបានដូចជាដើមអូលីវ នៅជុំវិញតុរបស់ឯង (ទំនុកដំកើង១២៨:៣)។**

សុភមង្គលនៅក្នុងគ្រួសារ ស្ថិតនៅលើសមាជិកគ្រួសារនីមួយៗចេះជួបជុំគ្នាអធិស្ឋានអានព្រះបន្ទូលជាទៀងទាត់។ ទម្លាប់នៃការជួបជុំគ្នាជាគ្រួសារ ដើម្បីអានព្រះបន្ទូលនិងអធិស្ឋាន មិនមែនគ្រាន់តែធ្វើអោយបង្គ្រប់កិច្ច ឬអោយគ្រាន់តែបានចប់នោះទេ ពោលគឺត្រូវធ្វើដោយមានលក្ខណៈរៀបរយ និងផ្តល់ពេលវេលាអោយបានគ្រប់គ្រាន់។ នៅក្នុងករណីសម្តែងក្នុងខខាងលើ ប្តី ប្រពន្ធកូនទាំងអស់ ត្រូវជួបជុំគ្នានៅជុំវិញតុ។

**មើល មនុស្សដែលកោតខ្លាចដល់ព្រះយេហូវ៉ា នឹងបានពរយ៉ាងនោះហើយ (ទំនុកដំកើង១២៨:៤)។**

កិរិយាកោតខ្លាចដល់ព្រះជាម្ចាស់ ជាប្រភពនៃសុភមង្គលនៅក្នុងគ្រួសារ។ កូនត្រូវមានសេចក្តីកោតខ្លាចដល់ព្រះជាម្ចាស់ ប្រពន្ធ ប្តី ក៏ត្រូវកោតខ្លាចដល់ព្រះជាម្ចាស់ដែរ។ ឪពុកម្តាយត្រូវធ្វើជាគំរូនៃការកោតខ្លាចដល់ព្រះជាម្ចាស់ ចំពោះបុត្រធីតារបស់ខ្លួន។ ការកោតខ្លាចដល់ព្រះជាម្ចាស់ មិនមែនគ្រាន់តែជាការនិយាយស្តីតែប៉ុណ្ណោះទេ។ ជីវិតរស់នៅប្រចាំថ្ងៃសម្តែងអោយឃើញថា មានការកោតខ្លាចដល់ព្រះ

ជាម្ចាស់តែម្តង។ កាលណាកូនឃើញឪពុកម្តាយធ្វើគំរូពីការកោតខ្លាចដល់ព្រះជាម្ចាស់ កូននឹងយកគំរូតាមឪពុកម្តាយជាប្រាកដ។ បញ្ហាដែលកើតឡើងនៅក្នុងគ្រួសារ ភាគច្រើនកើតមកពីការមិនកោតខ្លាចដល់ព្រះជាម្ចាស់។ កាលណាសមាជិកគ្រួសារនីមួយៗចេះកោតខ្លាចដល់ព្រះជាម្ចាស់ផ្ទាល់ខ្លួន បញ្ហាជាច្រើនត្រូវដោះស្រាយបានដោយខ្លួនឯង។

> **៥ព្រះយេហូវ៉ាទ្រង់នឹងប្រទានពរដល់ឯងពីក្រុងស៊ីយ៉ូនមក ហើយ**
> **ឯងនឹងបានឃើញសេចក្តីល្អ ដែលផ្សាយមកលើក្រុងយេរូសាឡិម**
> **ដរាបដល់អស់មួយជីវិតឯង ៦អើ ឯងនឹងបានឃើញចៅរបស់ឯង**
> **ដែរ សូមឱ្យមានសេចក្តីសុខគ្របលើ សាសន៍អ៊ីស្រាអែលផង**
> **(ទំនុកដំកើង១២៨:៥-៦)។**

ទាក់ទងនឹងសេចក្តីដែលសម្តែងនៅក្នុងខខាងលើ មានពាក្យទំនៀមមួយពោលថា "មុនធ្លាក់ ស្ថានសួគ៌ជាលំនៅដ្ឋានរបស់មនុស្សលោក ក្រោយធ្លាក់ មនុស្សលោកយកលំនៅដ្ឋានធ្វើជាស្ថានសួគ៌" តាមពិតទិសដៅដែលមនុស្សត្រូវទៅនៅអស់កល្បជានិច្ច គឺជាស្ថានសួគ៌ដែលព្រះរៀបចំសម្រាប់គេរៀងខ្លួន។ ប៉ុន្តែ ដោយសារអំពើបាបបានកាត់ផ្តាច់គេ គេនាំគ្នាសង់ផ្ទះរៀងៗខ្លួននៅលើផែនដីនេះ រួចរាប់ផ្ទះរបស់ខ្លួនថា ជាស្ថានសួគ៌សម្រាប់មួយជីវិតគេរស់នៅ។ ផ្ទះនៅផែនដី មិនមែនជា

ស្ថានសួគ៌សម្រាប់មនុស្សលោកទេ។ ផ្ទះគ្រាន់តែជាកន្លែងស្នាក់នៅបណ្តោះអាសន្នមួយដំណើរជីវិតតែប៉ុណ្ណោះ។ មនុស្សលោកគ្រប់រូបត្រូវឡើងថ្នាក់ខ្ពស់ជាង គឺត្រូវស្គាល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដើម្បីវិលត្រឡប់ទៅលំនៅស្ថានរបស់ខ្លួននៅឯស្ថានសួគ៌ ជាកន្លែងដែលព្រះជាម្ចាស់រៀបចំទុកអោយ។

# ជំពូក ១២៩-១៣០

***បាវចនា** ឆេះមិនសុះ*

ជំពូក១២៩ បរិយាយពីព្រឹត្តិការណ៍កាលរាស្ត្ររបស់ព្រះជាម្ចាស់នៅវ័យក្មេងនៅឡើយ។ ពេលនោះ អ្នកស្គាល់ព្រះជាម្ចាស់បានឃើញព្រះហស្តរបស់ព្រះអង្គបានប៉ះពាល់លើជីវិតគេ។ ដំណើរនេះ ជារូបភាពនៃសាសន៍អ៊ីស្រាអែលដែលត្រូវមនុស្សលោកបំផ្លាញចោល ប៉ុន្តែ មិនដែលផុតពូជពីលើលោកនេះទេ។ ដំណើរលោកម៉ូសេឃើញគុម្ពោតព្រៃឆេះដោយអណ្តាតភ្លើង តែឆេះមិនសុះនៅលើភ្នំស៊ីណាយ ជាគំរូពីព្រះជាម្ចាស់ទ្រង់រក្សាដល់រាស្ត្រព្រះអង្គគ្រប់រូប។ រូបភាពដែលយើងឃើញនៅក្នុងជំពូក ១២៩ ជារូបភាពរបស់យើងគ្រប់គ្នាជាកូនរបស់ព្រះអង្គ។ ព្រះអង្គការពាររាស្ត្រទ្រង់ជានិច្ច។

> **[១] គួរឱ្យសាសន៍អ៊ីស្រាអែលនិយាយឥឡូវថា តាំងពីខ្ញុំនៅក្មេងគេបានធ្វើទុក្ខខ្ញុំជាច្រើនដងហើយ [២] គឺតាំងពីខ្ញុំនៅក្មេង គេបានធ្វើទុក្ខខ្ញុំជាច្រើនដងមែន តែគេមិនបានឈ្នះខ្ញុំឡើយ (ទំនុកដំកើង ១២៩:១-២)។**

គ្មាននរណាម្នាក់ អាចបំផ្លាញរាស្ត្ររបស់ព្រះជាម្ចាស់អោយផុតពូជ ដោយសារព្រះជាម្ចាស់ទ្រង់ថែរក្សា។

**ហើយពួកអ្នកដែលដើរតាមទីនោះ ក៏មិនថា សូមឱ្យព្រះពរនៃព្រះយេហូវ៉ានៅលើឯងចុះ យើងឱ្យពរដល់ឯង ដោយនូវព្រះនាមព្រះយេហូវ៉ានោះឡើយ (ទំនុកដំកើង១២៩:៨)។**

"...សូមឱ្យព្រះពរនៃព្រះយេហូវ៉ានៅលើឯងចុះ..."។ ឃ្លានេះ មានវិសាលភាពទាំងវិស័យសាសនា វិស័យសង្គម វិស័យពាណិជ្ជកម្ម និងវិស័យនយោបាយ។ ក្នុងវិស័យពាណិជ្ជកម្មលោកបូអូសបានប្រើឃ្លានោះជាញឹកញាប់។ លោកមានប្រសាសន៍ទៅកាន់កម្មកររបស់លោកថា "សូមព្រះជាម្ចាស់គង់ជាមួយ ឯពួកកម្មករវិញ ក៏បានអោយពរដល់លោបូអូសវិញថា សូមព្រះជាម្ចាស់គង់ជាមួយលោកដែរ" (នាងរស់ ២:៤)។ នៅក្នុងវិស័យពាណិជ្ជកម្មបច្ចុប្បន្ន យើងមិនឃើញមានប្រើពាក្យនេះទាល់តែសោះ។

ជំពូក១៣០មានខ្លឹមសារស្រដៀងនិងជំពូក១២៩ដែរ។ បទគម្ពីរនេះមានឈ្មោះមួយទៀតហៅថា ជាបទគម្ពីរទំនុកដំកើងស្តីពីព្រះគុណនៃព្រះ។ សាវ័កប៉ុលរៀបរាប់ពីបណ្តាព្រះគុណរបស់ព្រះជាម្ចាស់ ស្រដៀងនិងបទគម្ពីរទំនុកដំកើងជំពូក១៣០នេះដែរ។ ព្រះជាម្ចាស់រំដោះមនុស្សលោកអោយរួចពីអំពើបាប មិនមែនដោយសារការ

ប្រព្រឹត្តរបស់មនុស្សលោកទេ គឺដោយសារព្រះគុណរបស់ទ្រង់វិញ។ ព្រះគុណរបស់ព្រះជាម្ចាស់ ផ្តល់មកដល់មនុស្សលោកតាមរយៈព្រះអម្ចាស់យេស៊ូវគ្រិស្តសុគតនៅលើឈើឆ្កាងជំនួសអំពើបាប ព្រមទាំងរស់ឡើងវិញដើម្បីផ្តល់សេចក្តីសុចរិតដល់អស់អ្នកណាដែលជឿព្រះអង្គ។ បណ្ឌិតម៉ាទីន-លូធ័រ បានអោយឈ្មោះគម្ពីរទំនុកដំកើងដូចខាងក្រោមនេះថា ជាទំនុកដំកើងប្រកបដោយព្រះគុណរបស់ព្រះជាម្ចាស់ដូចសាវ័កប៉ុលសម្តែងក្នុងគម្ពីរសញ្ញាថ្មី។ បទគម្ពីរទាំងនោះមានគម្ពីរទំនុកដំកើងជំពូក៣២ ៥១ ១៣០ និង១៤២។ ជំពូកទាំងអម្បាលមាណនេះ សុទ្ធតែរៀបរាប់ពីព្រះជាម្ចាស់ផ្តល់សេចក្តីសង្គ្រោះ ដល់មនុស្សលោកដោយសារព្រះគុណរបស់ទ្រង់។ មនុស្សលោកបានប្រព្រឹត្តអំពើបាបយ៉ាងសែនជ្រៅ តែព្រះជាម្ចាស់ផ្តល់ព្រះគុណ ដើម្បីដោះមនុស្សអោយរួចពីអំពើបាបរបស់ខ្លួន។

> **[១]ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានអំពាវនាវដល់ទ្រង់ ពីទីជំរៅមក [២]ឱព្រះអម្ចាស់អើយ សូមស្តាប់សំឡេងទូលបង្គំ សូមឲ្យព្រះកាណ៌ទ្រង់ប្រុងស្តាប់ពាក្យទូលបង្គំទូលអង្វរ [៣]ឱព្រះយេហូវ៉ាអើយ បើសិនជាទ្រង់កត់ចំណាំអស់ទាំងអំពើទុច្ចរិតនោះ ឱព្រះអម្ចាស់អើយ តើអ្នកណានឹងធន់នៅបាន (ទំនុកដំកើង១៣០:១-៣)។**

អរគុណដល់ព្រះជាម្ចាស់ណាស់ ដ្បិតព្រះអម្ចាស់ទ្រង់មិនដាក់ទោសយើង

អោយសមនឹងកិរិយាអាក្រក់ដែលយើងបានប្រព្រឹត្តទេ។ បើព្រះជាម្ចាស់ជំនុំជំរះយើងអោយសមនឹងកិរិយាដែលយើងបានប្រព្រឹត្ត យើងច្បាស់ជាបាត់បង់ទាំងអស់គ្នាជាមិនខាន។ ប៉ុន្តែ ព្រះអង្គបានផ្តល់ព្រះគុណដល់យើង ដើម្បីប្រោសយើងអោយរួចពីអំពើបាប។ ដោយសារមូលហេតុនេះ យើងត្រូវអរព្រះគុណដល់ព្រះជាម្ចាស់។

> **៤“ប៉ុន្តែទ្រង់មានព្រះហឫទ័យអត់ទោសវិញ ដើម្បីឱ្យគេបានកោត**
> **ខ្លាចដល់ទ្រង់ ៥“ទូលបង្គំរង់ចាំព្រះយេហូវ៉ា គឺព្រលឹងទូលបង្គំរង់ចាំ**
> **ទ្រង់ ទូលបង្គំសង្ឃឹមដល់ព្រះបន្ទូលនៃទ្រង់ ៦“ព្រលឹងនៃទូលបង្គំរង់**
> **ចាំព្រះអម្ចាស់ ជាជាងពួកយាមល្បាតរង់ចាំភ្លឺឡើង អើ ជាជាង**
> **ពួកយាមល្បាតរង់ចាំភ្លឺឡើងទៅទៀត (ទំនុកដំកើង១៣០:៤-៦)។**

សាសន៍អ៊ីស្រាអែលក៏ដូចជាសាសន៍ដទៃ។ គេត្រូវទទួលសេចក្តីសង្គ្រោះដោយសារព្រះគុណរបស់ព្រះជាម្ចាស់ តាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ សាសន៍អ៊ីស្រាអែលដែលបានប្រព្រឹត្តអំពើបាបយ៉ាងជ្រៅ ត្រូវការហៅរកព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលទ្រង់ជាអង្គសង្គ្រោះសម្រាប់ខ្លួនគេ ក៏ដូចជាសម្រាប់សាសន៍ដទៃដែរ។ គម្ពីររ៉ូមសម្តែងថា “នោះសាសន៍អ៊ីស្រាអែលទាំងអស់គ្នា នឹងបានសង្គ្រោះជាក្រោយ ដូចជាមានសេចក្តីចែងទុកមកថា “មានព្រះដ៏ប្រោសឱ្យរួច ទ្រង់នឹងចេញពីស៊ីយ៉ូនមក ទ្រង់នឹងបង្វែរសេចក្តីទមិលល្មើសពីយ៉ាកុបទៅ នោះហើយជាសេចក្តីសញ្ញាដែលអញតាំងនឹងគេ ក្នុង

កាលដែលអញបានដោះបាបគេចេញហើយ” ខាងឯដំណឹងល្អ គេជាខ្មាំងសត្រូវ ដើម្បីប្រយោជន៍ដល់អ្នករាល់គ្នា តែត្រង់សេចក្តីរើសតាំងនោះគេជាស្ងួនភ្ងាវិញ ដោយព្រោះពួកឰយុកោ” (រ៉ូម១១:២៦-២៨)។ កំពុងឆ្លងកាត់គ្រាមហាទុក្ខ សាសន៍អ៊ីស្រាអែលសេសសល់ទាំងអម្បាលមាណ រង់ចាំព្រះអម្ចាស់យេស៊ូវយាងមកដើម្បីសង្គ្រោះរូបគេ។ គេរង់ចាំព្រះអង្គដូចជារង់ចាំពេលព្រឹក។ ចំណែកយើងដែលជាអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទបច្ចុប្បន្ននេះ យើងក៏រស់នៅដើម្បីរង់ចាំអោយឃើញព្រះអម្ចាស់យេស៊ូវទ្រង់លេចមកដែរ។ ពេលព្រះអម្ចាស់ទ្រង់លេចមក ព្រះអង្គប្រមូលរាស្ត្ររបស់ទ្រង់ដើម្បីលើកគេទៅនៅជាមួយនឹងព្រះអង្គ។ គ្រានោះហៅថាគ្រាមហាសោមនស្ស។

# ជំពូក ១៣១

***ចំណងជើង*** *មានជំនឿដូចកូនក្មេង*

ជំពូក១៣១ខ្លី ប៉ុន្តែមានខ្លឹមសារយ៉ាងជ្រាលជ្រៅ។ ព្រះបាទដាវីឌបានកត់ត្រាសេចក្ដីដែលមានចែងនៅក្នុងគម្ពីរទំនុកដំកើងជំពូកនេះ។

> **១ឱព្រះយេហូវ៉ាអើយ ចិត្តទូលបង្គំមិនមែនធ្មើងឆ្មៃ ហើយភ្នែកទូលបង្គំក៏មិនប្រកាន់យស ទូលបង្គំមិនយកចិត្តទុកដាក់ក្នុងការដ៏ធំ ឬក្នុងដំណើរដែលអស្ចារ្យហួសល្បត់ទូលបង្គំឡើយ (ទំនុកដំកើង ១៣១:១)។**

ព្រះបាទដាវីឌមិនប្រកាន់យសថា ទ្រង់ជាក្សត្រផែនដីទេ។ ពេលស្ដេចអង្គនេះចូលមកចំពោះព្រះជាម្ចាស់ ស្ដេចអង្គនេះសម្ដែងការរីករាយសប្បាយនៅចំពោះព្រះអង្គប្រៀបឧបមាដូចជាកូនក្មេង។ ដោយសារស្ដេចអង្គនេះលោតរាំយ៉ាងសប្បាយនៅចំពោះវត្តមានរបស់ព្រះជាម្ចាស់ នាងមីកែលជាជាយារបស់ទ្រង់ បានមើលងាយព្រះបាទដាវីឌជាខ្លាំង។ រឿងនេះមានបរិយាយនៅក្នុងគម្ពីរ២សាំយ៉ូអែល៦:១២-២៣។ ឆ្លើយតបនឹង

សេចក្ដីមើលងាយពីសំណាក់ជាយាទ្រង់ ព្រះបាទដាវីឌមានបន្ទូលថា ទ្រង់នឹងធ្វើអោយអង្គកាន់តែទាបទៅ នៅចំពោះព្រះនេត្ររបស់ព្រះជាម្ចាស់។ ចំពោះនាងមីកែល ការថ្វាយបង្គំព្រះជាម្ចាស់នាងរាប់ថា ជាលក្ខណៈថោកទាប។ ចំពោះព្រះបាទដាវីឌវិញ ការថ្វាយបង្គំដល់ព្រះជាម្ចាស់ដោយលោតរាំដោយលុតជង្គង់ ឬដោយការប្រើកាយវិការគ្រប់បែបយ៉ាង ជារឿងដែលលោកពេញចិត្តនឹងបន្ទាបខ្លួននៅចំពោះព្រះជាម្ចាស់។ តើថ្មីៗនេះ លោកអ្នកបានលុតជង្គង់ថ្វាយបង្គំដល់ព្រះជាម្ចាស់ដែរឬទេ? ការលុតជង្គង់ថ្វាយបង្គំព្រះជាម្ចាស់ អាចជួយដល់ព្រលឹងរបស់លោកអ្នក ក៏ដូចជារូបកាយរបស់លោកអ្នកដែរ។

> **២ទូលបង្គំបានរំងាប់ ហើយព្រល្វងព្រលឹងទូលបង្គំជាស្រេច ដូច**
> **ជាក្មេងដែលម្ដាយបានផ្ដាច់ដោះឱ្យ គឺដូចជាក្មេងដែលលែងដោះ**
> **នៅជាមួយនឹងម្ដាយ អើ ព្រលឹងនៅក្នុងខ្លួនទូលបង្គំ ប្រៀបដូចជា**
> **កូនដែលលែងដោះហើយ ៣ឱអ៊ីស្រាអែលអើយ ចូរសង្ឃឹមដល់**
> **ព្រះយេហូវ៉ា ចាប់តាំងពីឥឡូវនេះ ដរាបដល់អស់កល្បជានិច្ចចុះ**
> **(ទំនុកដំកើង១៣១:២-៣)។**

តើយើងត្រូវមានអាកប្បកិរិយាបែបណា ដើម្បីដើរបែបគួរសមនៅចំពោះព្រះនេត្រព្រះជាម្ចាស់? បណ្ឌិតហ្គែប៊ីរឡេនបានបរិយាយថា យើងត្រូវមានគំនិតបន្ទាប

កាយបន្ទាបចិត្ត ដើម្បីដើរជាមួយនឹងព្រះជាម្ចាស់។ ការបន្ទាបកាយនិងបន្ទាបចិត្ត ជាកិរិយាសមរម្យសម្រាប់ការថ្វាយបង្គំដល់ព្រះជាម្ចាស់។ ទំនុកដំកើងជំពូក១៣៨:៦ សម្តែងថា "ដ្បិតទោះបើព្រះយេហូវ៉ាទ្រង់ខ្ពស់ គង់តែទ្រង់យល់ដល់ពួកអ្នករាបសាដែរ តែឯមនុស្សឆ្មើងឆ្មៃ ទ្រង់ស្គាល់គេពីចំងាយហើយ"។ គម្ពីរអេសាយ៥៧:១៥សម្តែងថា "ដ្បិតព្រះដ៏ជាធំ ហើយខ្ពស់បំផុត ជាព្រះដ៏គង់នៅអស់កល្បជានិច្ច ដែលព្រះនាមទ្រង់ជានាមបរិសុទ្ធ ទ្រង់មានបន្ទូលដូច្នេះថា អញនៅឯស្ថានដ៏ខ្ពស់ហើយបរិសុទ្ធ ក៏នៅជាមួយនឹងអ្នកណាដែលមានចិត្តសង្រេង ហើយទន់ទាប ដើម្បីនឹងធ្វើឱ្យចិត្តរបស់មនុស្សទន់ទាបបានសង្ឃឹមឡើង ហើយឱ្យចិត្តមនុស្សសង្រេងបានសង្ឃឹមឡើងដែរ"។ គម្ពីរ១ពេត្រុស៥:៥ចែងថា "ឯអ្នករាល់គ្នាដែលនៅក្មេង នោះត្រូវចុះចូលនឹងពួកចាស់ទុំដែរ ហើយត្រូវឱ្យគ្រប់គ្នាមានចិត្តសុភាព ដល់គ្នាទៅវិញទៅមក ពីព្រោះព្រះទ្រង់តែងតតាំងនឹងមនុស្សអួតអាង តែផ្តល់ព្រះគុណដល់ពួករាបសាវិញ"។ គម្ពីរ១ពេត្រុស៣:៤ចែងបន្ថែមទៀតថា "គឺតែងចំពោះមនុស្សលាក់កំបាំងក្នុងចិត្តវិញ ដោយគ្រឿងដ៏មិនចេះពុករលួយរបស់វិញ្ញាណសំឡូត ហើយរម្យទម នោះឯងជាសេចក្តីដែលមានដំឡៃវិសេសនៅចំពោះព្រះ"។ គម្ពីរយ៉ាកុប៤:១០សម្តែងថា "ចូរបន្ទាបខ្លួននៅចំពោះព្រះអម្ចាស់ នោះទ្រង់នឹងដំកើងអ្នករាល់គ្នាឡើង"។ ចុងក្រោយបង្អស់គឺគម្ពីរម៉ាថាយ១១:២៨ ព្រះអម្ចាស់យេស៊ូវគ្រីស្ទមានបន្ទូលពីព្រះឱស្ឋទ្រង់ផ្ទាល់ថា "អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឱ្យអ្នករាល់គ្នាឈប់សំរាក"។

កិរិយាបន្ទាបកាយ បន្ទាបចិត្តដូចជម្រាបជូនខាងលើ មិនអាចធ្វើទៅបានលើក

លែងតែបុគ្គលម្នាក់មានជំនឿជឿទុកចិត្តលើព្រះជាម្ចាស់ដូចជាកូនក្មេង។ បណ្ឌិត ហ្គែប៊ីរឡេនមានប្រសាសន៍ថា "ដូចជាកូនក្មេងទើបនឹងលែងបៅ កូននោះមិនត្រូវការទឹកដោះម្ដាយដើម្បីចិញ្ចឹមខ្លួនទៀតទេ ប៉ុន្តែ ទោះជាយ៉ាងនោះក៏ដោយ ក្មេងនោះសម្ដែងការដឹងគុណដល់ម្ដាយ ដ្បិតម្ដាយនោះជាម្ដាយរបស់ខ្លួនពិត"។ ការរស់នៅសង្ឃឹមដល់ព្រះយេហូវ៉ា ជាការរស់នៅសម្លឹងមើលទៅព្រះអង្គ អោយទ្រង់ដឹកនាំជីវិតរបស់យើងជារៀងរាល់ថ្ងៃ"។

យើងស្លេះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"